# អំពីខ្លឹមសារ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
# និងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

បទឧទ្ទេសនាមរបស់លោកជំទាវ **ស៊ុំ នីផា** សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ

នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ

ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣

សូមគោរព ឯកឧត្តម **ឯក សំអុល** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

សូមគោរព សម្តេច អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ សមាជិកសមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ

សូមគោរព លោក **ដោក ជា** នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ

សូមគោរព លោកគ្រូឧទ្ទេស និង គរុសិស្សទាំងអស់

សូមគោរព សមាជិកសមាជិកា នៃអង្គពិធីទាំងមូល

ខ្ញុំមានកិត្តិយសជម្រាបជូនគណៈអធិបតី សម្តេច អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ប្រិយមិត្តទាំងអស់ *នូវខ្លឹមសាររដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ* ។

បទឧទ្ទេសនាមរបស់ខ្ញុំផ្អែកទាំងស្រុងទៅលើអត្ថបទគតិយុត្តិគ្រឹះ ២ គឺ :

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលធ្វើវិសោធនកម្មនៅឆ្នាំ ១៩៩៤ ឆ្នាំ ១៩៩៩ ឆ្នាំ ២០០១ ឆ្នាំ ២០០៤ ឆ្នាំ ២០០៥ ឆ្នាំ ២០០៦ និងឆ្នាំ ២០០៨
- និងច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ហើយដែលបានធ្វើវិសោធនកម្មដោយព្រះរាជក្រម លេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ។

## I — អំពីខ្លឹមសាររដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញជាច្បាប់កំពូល ដែលរាល់ច្បាប់និងឯកសារគតិយុត្តិទាំងឡាយក្នុងប្រទេសនីមួយៗត្រូវអនុលោមតាម ។ រដ្ឋធម្មនុញ្ញជាប្រភពនៃភាពត្រូវច្បាប់ ។ រដ្ឋធម្មនុញ្ញបានបង្កើតអំណាចសាធារណៈ កំណត់អំពីសមត្ថកិច្ច និងចាត់ចែងការទាក់ទង រវាងអំណាចសាធារណៈទាំងនោះដែលបែងចែកដាច់ពីគ្នារវាង អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ និងកំណត់អំពីរបបនយោបាយ ទង់ជាតិ និងភ្លេងជាតិ។ រដ្ឋធម្មនុញ្ញចែកជា១៦ជំពូកដែលមានសរុបទាំងអស់១៥៨មាត្រា តទៅនេះសូមជូនខ្លឹមសាររដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ដោយសង្ខេប :

១- ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិប-តេយ្យសេរីពហុបក្ស ។ ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ អព្យាក្រឹត អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ។

២- ក្នុងរបបព្រះរាជាណាចក្រទី២ **អំណាចទាំងអស់ចេញមកពីប្រជាពលរដ្ឋ** ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី។

៣- រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ជារដ្ឋធម្មនុញ្ញនៃប្រទេសនីតិរដ្ឋ ពីព្រោះស្ថាប័នកំពូលមួយឈ្មោះថា ក្រុមប្រឹក្សា-ធម្មនុញ្ញ ដែលជាអ្នកការពារការគោរពរដ្ឋធម្មនុញ្ញ និងច្បាប់នានា ។ ម្យ៉ាងទៀតរដ្ឋធម្មនុញ្ញមានចែងអំពី **អំណាចតុលាការ**ឯករាជ្យដែលជាលក្ខណៈមួយទៀតនៃប្រទេសនីតិរដ្ឋ ។ មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី ។ គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬ អំណាចនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ ។មានតែអង្គការអយ្យាការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យភាពនៃអំណាចតុលាការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។

៤- រដ្ឋធម្មនុញ្ញលើកតម្កើងភាសា និងអក្សរខ្មែរ ដែលត្រូវប្រើជាផ្លូវការ និង លើកតម្កើងព្រះពុទ្ធសាសនាដែលត្រូវចាត់ទុកជាសាសនារបស់រដ្ឋ ។

៥- **ស្ថាប័នរដ្ឋសភាជាស្ថាប័នកំពូលមួយ** ដែលមានអំណាចធំជាងគេ ក្នុងចំណោមស្ថាប័ននយោបាយកំពូលដ៏ទៃទៀត ដែលជាលក្ខណៈពិសេសនៃរបបលទ្ធិប្រជាធិបតេយ្យសេរីសភានិយម ។ រាជរដ្ឋាភិបាលទទួលខុសត្រូវចំពោះមុខរដ្ឋសភាតែមួយគត់។ ក្នុងកាលៈទេសៈស្ថិតនៅក្នុងភាពអាសន្ន រដ្ឋសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ហើយនៅពេលដែលប្រទេសជាតិឋិតក្នុងភាពអាសន្ន រដ្ឋសភាមិនអាចត្រូវរំលាយបានឡើយ ។ ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួន ៣០ នាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

៦- **គណៈរដ្ឋមន្ត្រី** ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក ។ នាយករដ្ឋមន្ត្រីត្រូវតែជាឥស្សរជនដែលចេញមកពីគណបក្សឈ្នះឆ្នោត ។ សមាជិកម្នាក់ៗរបស់រាជរដ្ឋាភិបាលទទួលខុសត្រូវរៀងៗខ្លួនចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភា ។ បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មីក្នុងលក្ខខណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ដើម្បីទៅជាសមាជិកនៃរាជរដ្ឋាភិបាលបាន ត្រូវតែជាសមាជិករបស់គណបក្សដែលមានអាសនៈក្នុងសភាជាមុន ។

៧- **ព្រឹទ្ធសភា** ជាអង្គការនីតិបញ្ញត្តិកំពូលមួយ ដែលមានភារកិច្ចសម្របសម្រួលការងារ រវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ។ ក្នុងវិស័យនៃការធ្វើច្បាប់ ព្រឹទ្ធសភាពិនិត្យនិងឱ្យយោបល់ ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមនិងបញ្ជូនមក ។ ប៉ុន្តែបើជាកិច្ចការ

ប្រញាប់ រយៈពេលនេះត្រូវបន្ថយត្រឹមតែ ៥ថ្ងៃ ។ ទោះបីព្រឹទ្ធសភា បានឱ្យយោបល់យល់ព្រម ឬពុំបានឱ្យយោបល់សោះ ក្នុងរយៈពេលដូចបានជម្រាបជូនខាងលើ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះនឹងត្រូវបានយកទៅប្រកាសឱ្យប្រើ ។

៨- រដ្ឋធម្មនុញ្ញលើកតម្កើងសិទ្ធិនារី ឱ្យស្មើគ្នានឹងសិទ្ធិបុរស ទាំងក្នុងផ្នែកនយោបាយ សេដ្ឋកិច្ច សង្គម អាពាហ៍ពិពាហ៍ និងគ្រួសារ ។ សព្វថ្ងៃនេះយើងកំពុងតែអនុវត្តជាក់ស្តែងនូវចំណុចនេះទាំងក្នុងក្របខ័ណ្ឌយេនឌ័រ (Gender) ក៏ដូចក្នុងក្របខ័ណ្ឌដ៏ទៃទៀត ។ ការងារស្ត្រីមេផ្ទះមានតម្លៃស្មើការងារបុរស ។

៩- រដ្ឋយកចិត្តទុកដាក់ខ្ពស់ចំពោះអនាគតយុវជនយុវនារីទាំងអស់ ដោយតម្រូវឱ្យមានការទទួល**អប់រំចំណេះវិជ្ជា**ទូទៅ សម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ ។ ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិច ៩ឆ្នាំ ។ រាជរដ្ឋាភិបាលបច្ចុប្បន្នកំពុងខិតខំបំពេញកាតព្វកិច្ចរដ្ឋនេះយ៉ាងមមាញឹកបំផុត ដែលជាហេតុបណ្តាលឱ្យមានសាលារៀនគ្រប់ភូមិសិក្សា គ្រប់ទីតំបន់ រហូតទៅដល់ទីតំបន់ដាច់ស្រយាលផង ។

១០- រដ្ឋធានា**សុខភាពរបស់ប្រជាពលរដ្ឋ** ។ ក្នុងចំណុចនេះរាជរដ្ឋាភិបាលកំពុងតែសកម្មក្នុងការបង្កើតមន្ទីរពេទ្យ គិលានដ្ឋាន និង មន្ទីរសម្ភពសាធារណៈ ។

១១- ព្រះរាជាណាចក្រកម្ពុជាអនុវត្ត**ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី** ដែលខុសពីរបបសង្គមនិយមកន្លងមក ដោយជំរុញឱ្យមានការប្រកួតប្រជែងនៅលើទីផ្សារ និងដោយមានវិនិយោគិនបរទេសចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចផង ។

១២- ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និង**គោរពសិទ្ធិ**មនុស្សដូចជា សិទ្ធិរស់រានមានជីវិត សិទ្ធិដើរឆ្ងាយជិត សិទ្ធិក្នុងការបញ្ចេញមតិ និងសិទ្ធិសេរីភាពខាងជំនឿជាដើម ។ ព្រះមហាក្សត្រជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួន របស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដ៏ទៃឡើយ ជាករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ។ ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។ ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។ វិមតិសង្ស័យត្រូវជាប្រយោជន៍ដល់ជនជាប់ចោទ ។

១៣- ប្រជាពលរដ្ឋត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ។

១៤- **ព្រះមហាក្សត្រ**ទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែមិនកាន់អំណាចឡើយ ។ ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ។ អង្គព្រះមហាក្សត្រមិនអាចនរណារំលោភបំពានបានឡើយ ។ ព្រះមហាក្សត្រទ្រង់មានតួនាទីជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈ ឱ្យមានភាពទៀងទាត់ ។ ព្រះមហាក្សត្រទ្រង់ឥតមានព្រះរាជអំណាចចាត់តាំងព្រះរាជទាយាទសម្រាប់គ្រងរាជសម្បត្តិឡើយ ។ របបរាជានិយមកម្ពុជាជារបបជ្រើសតាំង ។ នៅពេល

ប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិឋិត ក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ពីប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្រោមព្រះរាជាធិបតីរបស់ព្រះមហាក្សត្រ ។ ព្រះមហាក្សត្រទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ហើយទ្រង់គង់ជាព្រះរាជាធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

១៥- ព្រះមហាក្សត្រទ្រង់គង់ជាព្រះរាជាធិបតីនៃ**សមាជជាតិ** ដែលត្រូវកោះប្រជុំដោយនាយករដ្ឋមន្ត្រី មួយដងក្នុងមួយឆ្នាំ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជ នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

១៦- ក្នុងករណីចាំបាច់រដ្ឋសភា និងព្រឹទ្ធសភា អាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ។ តាមសេចក្ដីសម្រេចលេខ ១១២/00៥/២០១០ កបធ.ច ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១០ កិច្ចប្រជុំ**សមាជព្រឹទ្ធសភា និងរដ្ឋសភា** ត្រូវដឹកនាំដោយប្រធានព្រឹទ្ធសភានិងប្រធានរដ្ឋសភាជាសហប្រធាន បានតែក្នុងនីតិកាលទី១ នៃព្រឹទ្ធសភាតែប៉ុណ្ណោះ ។ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជព្រឹទ្ធ-សភា និងរដ្ឋសភា ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/0២១១/00៥ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១១ ក្រោយដែលក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យជាមុន ។ តាមច្បាប់នេះ ប្រធានព្រឹទ្ធសភាជាប្រធានសមាជ ។

១៧- ក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នឯករាជ្យ អព្យាក្រឹត ដែលពុំស្ថិតនៅក្នុងអំណាចណាមួយ នៃអំណាចទាំងបី គឺ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ ។ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បានចែងក្នុងជំពូកមួយដោយឡែកគឺ ជំពូកទី ១២ អំពីក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានសមត្ថកិច្ចដូចខាងក្រោម :

## II – <u>អំពីសមត្ថកិច្ច របស់ក្រុមប្រឹក្សាធម្មនុញ្ញ</u>

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ច ធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ និង ពិនិត្យសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ( មាត្រា ១៣៦ថ្មី នៃរដ្ឋធម្មនុញ្ញ) ។ បទឧទ្ទេសនាមរបស់ខ្ញុំថ្ងៃនេះចែកជា ៣ ផ្នែក :

- សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងការធានា ការពារ ការគោរពរដ្ឋធម្មនុញ្ញ
- សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះធម្មនុញ្ញភាព និង ការបកស្រាយរដ្ឋធម្មនុញ្ញនិងច្បាប់
- សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងករណីវិវាទកម្មទាក់ទងនឹង ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

### ១_ សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងការធានា ការពារ ការគោរពរដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់ និង សេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត (មាត្រា ១៥០ថ្មី នៃរដ្ឋធម្មនុញ្ញ) ។

ការផ្តើមគំនិតសើរើ ឬធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និង របស់ប្រធានរដ្ឋសភាតាមសេចក្តីស្នើរបស់តំណាងរាស្ត្រ ១/៤ នៃចំនួនសមាជិករដ្ឋសភាទាំងមូល (មាត្រា ១៥១ថ្មី នៃរដ្ឋធម្មនុញ្ញ) ។ ព្រះមហាក្សត្រទ្រង់**ពិគ្រោះមតិ** ក្រុមប្រឹក្សាធម្មនុញ្ញចំពោះសេចក្តីស្នើទាំងឡាយណា ដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ (មាត្រា ១៤៣ថ្មី នៃរដ្ឋធម្មនុញ្ញ) ។

ការសើរើ ឬធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ **ត្រូវហាមឃាត់**មិនឱ្យធ្វើនៅពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ឬកាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និង របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។

ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ ដែលមាន**សមត្ថកិច្ចសម្រេចពីមោឃភាព**នៃការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬ ការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ (មាត្រា ៩២ នៃរដ្ឋធម្មនុញ្ញ) ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេច **បិទផ្លូវតវ៉ា** ហើយមានអានុភាពអនុវត្តទៅលើគ្រប់អំណាចទាំងអស់ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ (មាត្រា ១៤២ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ២៣ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ) ។

(សូមមើលស្លាយដែលមានចំណងជើងថា "ព្រះមហាក្សត្រនិងក្រុមប្រឹក្សាធម្មនុញ្ញ")




**កំណត់សម្គាល់**

❶ : ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយណាដែលសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ

❷ : ធ្វើសំណើថ្វាយព្រះមហាក្សត្រទ្រង់ព្រះតម្រិះពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ

❸ : មតិក្រុមប្រឹក្សាធម្មនុញ្ញថ្វាយព្រះមហាក្សត្រ

❹ : ព្រះរាជសារទៅម្ចាស់សំណើវិញ

## ២-សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះធម្មនុញ្ញភាព និង ការបកស្រាយរដ្ឋធម្មនុញ្ញនិងច្បាប់

ក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយរដ្ឋធម្មនុញ្ញ និង បកស្រាយច្បាប់ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាព តាមសំណើពីព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និង នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួន ១/៤ ឬតំណាងរាស្ត្រ ១/១០ ឬតុលាការ (តុលាការចំពោះតែច្បាប់ណាដែលប្រកាសឱ្យប្រើហើយ) ។

ក្រុមប្រឹក្សាធម្មនុញ្ញអាចធ្វើការពិនិត្យនូវធម្មនុញ្ញភាពនៃច្បាប់ **ជាអាទិកាល** (**a priori**) ។ គឺមុនប្រកាសឱ្យប្រើច្បាប់ (មាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា១៦ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ) និងពេលក្រោយពីការប្រកាសឱ្យប្រើច្បាប់**ជាបច្ឆាកាល** (**a posteriori**) (មាត្រា១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៨ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ) ។

(សូមមើលស្លាយដែលមានចំណងជើងថា "**ក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ**")




### ក- ការពិនិត្យជាអាទិកាល

អ្នកស្នើគឺជាស្ថាប័នដែលមានចែងដោយរដ្ឋធម្មនុញ្ញ ដូចជាព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា សមាជិក ១/៤ នៃសមាជិកព្រឹទ្ធសភា ឬសមាជិក ១/១០ នៃសមាជិករដ្ឋសភា ។ អ្នកស្នើដូចរៀបរាប់ខាងលើ អាចប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ដែលអនុម័តដោយរដ្ឋសភា និងពិនិត្យចប់សព្វគ្រប់ ដោយព្រឹទ្ធសភា **មុនពេលប្រកាសឱ្យប្រើ** (**a priori**) ។ ចំណុចនេះ ជាជម្រើសពុំមែនជាកាតព្វកិច្ចឡើយ ។ ក៏ប៉ុន្តែ បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងព្រឹទ្ធសភា ក៏ដូចជាច្បាប់រៀបចំអង្គការមុននឹងប្រកាសឱ្យប្រើ**ត្រូវតែបញ្ជូនជាដាច់ខាតមកក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យធម្មនុញ្ញភាព** ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចតបវិញក្នុងរយៈពេល ៣០ថ្ងៃ ( មាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ថ្មី នៃ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ) ឬក្នុងករណីកិច្ចការប្រញាប់ ត្រូវតបវិញក្នុងរយៈពេល ៨ថ្ងៃ ( មាត្រា ២២ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ) ។

**ខ- ការពិនិត្យជាបច្ឆាកាល**

**ក្រោយពីបានត្រូវប្រកាសឱ្យប្រើហើយ(a posteriori)** ច្បាប់ទាំងឡាយអាចដាក់មកក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យធម្មនុញ្ញភាព ដោយអ្នកស្នើសុំជាស្ថាប័នដែលមានចែងក្នុងរដ្ឋធម្មនុញ្ញដូចលើកឡើងខាងលើ **ឬដោយតុលាការ** ។ **អ្នកស្នើសុំឯកជន** ក៏អាចប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញឱ្យធ្វើការពិនិត្យដូចគ្នានេះបានផងដែរ តែត្រូវធ្វើឡើងតាមរយៈ តំណាងរាស្ត្រ ឬ ប្រធានរដ្ឋសភា ឬ សមាជិកព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា ( មាត្រា ១៤១ថ្មី វាក្យខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ថ្មី នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ) ។

( សូមមើលស្លាយដែលមានចំណងជើងថា "ក្រុមប្រឹក្សាធម្មនុញ្ញនិងប្រជារាស្ត្រ")




**គ- នីតិវិធីពិសេស**

**ភាគីជាប់ពាក់ព័ន្ធរឿងក្តីណាមួយអាចលើកឡើងពីបញ្ហាបន្ទាន់បង្គំស្តីពីធម្មនុញ្ញភាព** (question préjudicielle ou question prioritaire de constitutionnalité) ជូនតុលាការ ប្រសិនបើភាគីក្តីនោះយល់ថា ច្បាប់ដែលអនុវត្តនោះ

មិនស្របនឹងរដ្ឋធម្មនុញ្ញ ឬ យល់ឃើញថា សេចក្ដីសម្រេចរបស់ស្ថាប័នសាធារណៈសម្រាប់ករណីនោះមានការរំលោភសិទ្ធិជាសារវ័ន្តរបស់ខ្លួន ដែលធានាដោយរដ្ឋធម្មនុញ្ញ ។ ប្រសិនបើតុលាការវិនិច្ឆ័យថា សំណើនោះមានមូលដ្ឋានត្រឹមត្រូវហើយ តុលាការគ្មានសមត្ថកិច្ចដើម្បីពិនិត្យបញ្ហាអធម្មនុញ្ញភាពនោះ តុលាការត្រូវបញ្ជូនសំណើនោះមកឱ្យតុលាការកំពូលក្នុងរយៈពេល ១០ថ្ងៃ ។ តុលាការកំពូលពិនិត្យសំណុំរឿងនោះ ហើយបញ្ជូនមកក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ថ្ងៃ លើកលែងតែខ្លួនយល់ថា សំណើនេះមិនអាចទទួលយកបាន (មាត្រា ១៩ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ) ។ ប្រៀបធៀបទៅនឹងនីតិវិធីសាមញ្ញ វាមានភាពខុសប្លែកគ្នាក្នុងខ្លឹមសារដែលត្រង់ចំណុចនេះ តុលាការមិនបានធ្វើអន្តរាគមន៍ ដោយខ្លួនឯងនៅក្នុងនីតិវិធីនៃការប្ដឹងមកក្រុមប្រឹក្សាធម្មនុញ្ញទេ គឺភាគីនៃរឿងក្ដីជាអ្នកធ្វើសំណើឡើងនោះ ។ ដូច្នេះ នីតិវិធីនេះ គឺជានីតិវិធីអញ្ញត្រកម្ម (procédure d’exception) ។

## ៣_ សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងករណីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

### ក- ក្រុមប្រឹក្សាធម្មនុញ្ញ និង ការចុះឈ្មោះគណបក្សនយោបាយ

(សូមមើលស្លាយដែលមានចំណងជើងថា "ក្រុមប្រឹក្សាធម្មនុញ្ញនិងគណបក្សនយោបាយ")




**កំណត់សម្គាល់**

❶ : បណ្ដឹងរបស់គណបក្សនយោបាយដែលក្រសួងមហាផ្ទៃបានបដិសេធមិនព្រមចុះបញ្ជីគណបក្សនយោបាយ

❷ : បណ្ដឹងឧទ្ធរណ៍មិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប. (រយៈពេលមាន ៥ ថ្ងៃ ឬ ៧២ ម៉ោង ទៅតាមករណីនីមួយៗ)

❸ : បណ្ដឹងផ្ទាល់មិនសុខចិត្តអំពីលទ្ធផលបោះឆ្នោតបណ្ដោះអាសន្ន ប្រកាសដោយ គ.ជ.ប.

ប្រសិនបើក្រសួងមហាផ្ទៃបដិសេធការចុះឈ្មោះបញ្ជីគណបក្សមួយ គណបក្សនោះ អាចដាក់ពាក្យបណ្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ហើយក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចករណីនេះ យ៉ាងយូរក្នុងរយៈពេល ៣០ថ្ងៃបន្ទាប់។ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចលើភាពត្រឹមត្រូវរបស់គណបក្សនេះរួចហើយ ក្រសួងមហាផ្ទៃត្រូវចុះបញ្ជី គណបក្សនោះភ្លាម (មាត្រា ២៥ នៃច្បាប់ស្តីពីគណបក្សនយោបាយ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨)។ គួរកត់សម្គាល់ផងដែរថា នៅក្នុងនីតិវិធីនេះ **ប្រជាពលរដ្ឋសាមញ្ញម្នាក់ៗ**អាចដាក់ពាក្យបណ្តឹងត្រង់មកក្រុមប្រឹក្សាធម្មនុញ្ញបាន។

### ខ- បណ្តឹងទាក់ទងនឹងការបោះឆ្នោត

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចសម្រេចចំពោះបណ្តឹងទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាតែប៉ុណ្ណោះ ។ ក្រុមប្រឹក្សាធម្មនុញ្ញមិនមានសមត្ថកិច្ចក្នុងការបោះឆ្នោតថ្នាក់មូលដ្ឋាន ដូចជាការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ជាដើមទេ **លើកលែងតែ**ការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតឃុំ សង្កាត់។ ចំពោះសមត្ថកិច្ចចុងក្រោយនេះ ក្រុមប្រឹក្សាធម្មនុញ្ញមានតួនាទីដូចជាតុលាការ ដែលប្រើនីតិវិធីតុលាការក្នុងការស៊ើបអង្កេត និង នីតិវិធីសួរដេញដោលទល់មុខ ឬ ការវិនិច្ឆ័យក្នុងសវនាការបើកចំហរ ។ មេធាវីត្រូវទទួលអនុញ្ញាតឱ្យការពារតំណាង និងជួយដល់ភាគីនីមួយៗ ។ សាក្សី និងភស្តុតាងទាំងអស់ ត្រូវយកមកបង្ហាញចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញ ។ មុននឹងធ្វើការវិនិច្ឆ័យ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំង ៩ រូប ត្រូវពិភាក្សាក្នុងបន្ទប់សម្ងាត់ ដោយគ្មាននរណាទៀតចូលរួម ។ ជាទូទៅគូភាគីច្រើនតែជាគណបក្សនយោបាយ ហើយនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ វិវាទតែងតែទាក់ទងទៅនឹងការចុះបញ្ជីឈ្មោះ និង លទ្ធផលនៃការបោះឆ្នោត នៅក្នុងមណ្ឌលបោះឆ្នោតនានា ។

ទាក់ទងនឹងលទ្ធផលនៃការបោះឆ្នោត អ្នកប្តឹង (គណបក្សនយោបាយ ឬ បុគ្គល) អាចដាក់ពាក្យបណ្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៧២ម៉ោង បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ន ឬបន្ទាប់ពីការប្រកាសសេចក្តីជូនដំណឹងនៃការបដិសេធរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ សម្រាប់ករណីទាំងនេះ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្តីសម្រេចក្នុងរយៈពេល ២០ថ្ងៃ ។ ពាក្យបណ្តឹងតវ៉ាគ្មានអានុភាពផ្អាកការអនុវត្តទេ ប៉ុន្តែ បើយល់ថាចាំបាច់ ក្រុមប្រឹក្សាធម្មនុញ្ញអាចចេញ បញ្ជាការព្យួរបណ្តោះអាសន្ន នូវលទ្ធផលដោយឡែកដែលទាក់ទងនឹងបេក្ខភាពរបស់សមាជិករដ្ឋសភា ឬ សមាជិកព្រឹទ្ធសភានៃមណ្ឌលណាមួយ ។

មុននឹងបញ្ចប់ខ្ញុំសូមធ្វើការកត់សម្គាល់ ៤ចំណុច ដូចតទៅ :

១- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវផ្ញើថ្វាយព្រះមហាក្សត្រ ជូនប្រធានព្រឹទ្ធសភា ជូនប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងប្រធានតុលាការកំពូល និងចុះផ្សាយក្នុងរាជកិច្ច ។ ប្រធានព្រឹទ្ធសភា ត្រូវជូនដំណឹងសេចក្តីសម្រេចនេះដល់សមាជិកព្រឹទ្ធសភាទាំងអស់។ ប្រធានរដ្ឋសភា ត្រូវជូនដំណឹងសេចក្តីសម្រេចនេះដល់សមាជិករដ្ឋសភាទាំងអស់ ។ នាយករដ្ឋមន្ត្រីត្រូវជូនដំណឹងសេចក្តីសម្រេចនេះដល់សមាជិករាជរដ្ឋាភិបាលទាំងអស់។

ប្រធានតុលាការកំពូល ត្រូវជូនដំណឹងសេចក្ដីសម្រេចនេះដល់តុលាការសាម៉ី ( មាត្រា ២៤ថ្មី នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធមនុញ្ញ) ។

២- ជនណាដែលមិនព្រមគោរពតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឬ រារាំងដល់កិច្ចប្រតិបត្តិការរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពីមួយខែដល់មួយឆ្នាំ និង **ត្រូវពិន័យ**ជាប្រាក់ពីដប់ម៉ឺន (១០០.០០០)រៀល ដល់ ហុកសិបម៉ឺន (៦០០.០០០)រៀល ឬ**ផ្ដន្ទាទោស**ណាមួយក្នុងចំណោមទោសទាំងពីរ ។

៣- ជាគោលការណ៍របស់ក្រុមប្រឹក្សាធម្មនុញ្ញ កបធ មិនធ្វើស្វ័យបណ្ដឹងខ្លួនឯងទេ (auto-saisine)

៤- ជាព័តិមាននៅក្នុងឆ្នាំ ២០០៨ រដ្ឋធម្មនុញ្ញបារាំងទើបនឹងរាប់បញ្ចូលការពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាលក្នុងករណី**បញ្ហាបន្ទាន់បង្ខំនៃធម្មនុញ្ញភាព** ដែលប្រហាក់ប្រហែលនឹងច្បាប់ខ្មែរដែរ ហើយដែលត្រូវបានអនុវត្តចាប់តាំងពីថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១០។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្ដាប់បទឧទ្ទេសនាមនេះ ពីសំណាក់ សម្ដេច ឯកឧត្ដម លោកជំទាវ លោក លោកស្រី និងអ្នកនាងកញ្ញាទាំងអស់ដែលមានវត្តមាននៅទីនេះ ។

**សូមអរគុណ**